# សិទ្ធិប្រើប្រាស់ស្មើភាពគ្នាចំពោះសេវា **DSHS**

បើអ្នកមានជម្ងឺពិការ, ស្ថានភាពវេជ្ជសាស្ត្រ ឬសតិបញ្ញា, ឬបញ្ហាក្នុងការអាន និងការសរសេរ, ឬបញ្ហាក្នុងការរៀនសូត្រ, នោះយើងនឹងចាត់វិធានការបន្ថែម ឬអនុវត្តយុទ្ធវិធីផ្សេងៗទៀត ដើម្បីជួយអ្នកឲ្យអាចទទួលបាន ឬរក្សាទុកសេវាបម្រើរបស់យើង។ ជំនួយដែលយើងផ្តល់ជូនអ្នកគឺផ្អែកលើមូលដ្ឋាននៃសេចក្តីត្រូវការនានារបស់អ្នក។

យើងនឹងសុំឲ្យអ្នកជួយរិះរកមធ្យោបាយដ៏មានប្រសិទ្ធភាពល្អបំផុតមួយ ដែលយើងអាចជួយអ្នកបាន។ អ្នកមិនចាំបាច់ឆ្លើយនឹងសំណួរស្តីពីសិទ្ធិប្រើប្រាស់ស្មើភាពគ្នា (Equal Access) ទេ ដើម្បីឲ្យមានលក្ខណៈទទួលជំនួយនោះ។

អ្នកអាចសុំយើង ឲ្យជួយផ្តល់ជំនួយការជាបន្ថែមនៅពេលណាក៏បាន។

បើអ្នកត្រូវការជំនួយការបន្ថែម, នោះយើងនឹងធ្វើការជាមួយអ្នក ដើម្បីជួយរៀបចំផែនការសិទ្ធិប្រើប្រាស់ស្មើភាពគ្នាជាមួយគ្នា។

យើងនឹងប្រគល់ជូនអ្នកនូវសំណៅចម្លងនៃផែនការសិទ្ធិប្រើប្រាស់ស្មើភាពគ្នារបស់ផងអ្នក។ យើងក៏អាចប្រគល់សំណៅចម្លងនេះជូនទៅជនដទៃៗទៀត ដែលជួយអ្នកក្នុងការធ្វើក្រដាសស្នាមដើម្បីទទួលសេវាបម្រើរបស់យើងដែរ។

## នេះគឺជាមធ្យោបាយខ្លះៗ ដែលយើងអាចជួយដល់អស់អ្នកដែលត្រូវការជំនួយការបន្ថែម ៖

- ✓ ជួយបំពេញទម្រង់ DSHS
- ✓ រៀបចំឧបករណ៍ជំនួយក្នុងការស្តាប់, អ្នកបកប្រែភាសាគ, ឬជំនួយក្នុងការប្រស្រ័យទាក់ទងផ្សេងៗទៀត
- ✓ ផ្ញើទម្រង់ និងសំបុត្រស្នាមនានាជាសំណៅអក្សរធំ, តាមប្រព័ន្ធអេឡិចត្រូនិច, ឬតាមទ្រង់ទ្រាយផ្សេងៗ
- ✓ អាន ឬពន្យល់អត្ថន័យក្នុងសំបុត្រស្នាម ឬក្នុងទម្រង់ដែលយើងផ្ញើទៅជូនអ្នក
- ✓ ជួយទទួលព័ត៌មានដែលយើងត្រូវការ ឲ្យទាន់តាមកាលបរិច្ឆេទដែលយើងត្រូវការវា
- ✓ ផ្ញើសំណៅចម្លងនៃសំបុត្រស្នាមនានាជូនទៅ ឬទាក់ទងជាមួយជនណាម្នាក់ ដែលជួយអ្នក
- ✓ ផ្តល់សិទ្ធិជូនជនដែលអ្នកបានជ្រើសរើស ឲ្យទទួលខុសត្រូវលើប្រាក់កាស, ម្ហូបអាហារ, និង/ឬជំនួយវេជ្ជសាស្ត្ររបស់អ្នក
- ✓ ផ្តល់ពេលវេលាបន្ថែមដល់ការឆ្លើយតបមកយើង ឬការរកព័ត៌មានឲ្យយើង
- ✓ ទូរស័ព្ទទៅជួបអ្នកនៅឯផ្ទះ ជាជាងឲ្យអ្នកមកជួបយើងនៅនឹងការិយាល័យផ្ទាល់
- ✓ ជួបជាមួយអ្នកនៅក្នុងបន្ទប់ណាមួយដែលគ្មានការរំខាន
- ✓ ទូរស័ព្ទទៅប្រាប់អ្នកឲ្យដឹងជាមុន មុននឹងយើងបដិសេធ, បញ្ឈប់, ឬកាត់បន្ថយជំនួយរបស់អ្នក, ហើយបើអ្នកមិនយល់ស្របជាមួយនឹងការសម្រេចរបស់យើង, នោះយើងជួយសុំឲ្យមានការបើកសវនាការណាមួយ និង/ឬស្នើសុំឲ្យគេបន្តជំនួយជូនអ្នក
- ✓ រំលឹកប្រាប់អ្នកអំពីការណាត់ជួប
- ✓ ទាក់ទងទៅអ្នក ប្រសិនបើអ្នកភ្លេចការណាត់ជួប ឬភ្លេចថ្ងៃកំណត់
- ✓ ពិនិត្យមើលការសម្រេចករណីបញ្ឈប់ ឬកាត់បន្ថយជំនួយឡើងវិញដើម្បីឲ្យប្រាកដថា យើងបានអនុវត្តតាមផែនការសិទ្ធិប្រើប្រាស់ស្មើភាពគ្នារបស់ផងអ្នក
- ✓ ផ្តល់ជូនអ្នកនូវជំនួយការផ្សេងៗទៀត ដែលអ្នកត្រូវការក្នុងការទទួល ឬការរក្សាទុកសេវាបម្រើរបស់យើង

បទបញ្ញត្តិនានាដែលយើងយកមកអនុវត្តសំរាប់សិទ្ធិប្រើប្រាស់ស្មើភាពគ្នានេះគឺនៅក្នុងកម្រងក្រមរដ្ឋបាលរដ្ឋវ៉ាស៊ីនតោន *(WAC) 388-472-0010* រហូតដល់ *-0050* ក្រោមកិច្ចសម្របសម្រួលបន្ថែមជាចាំបាច់ *(Necessary Supplemental Accommodation)* ។

Washington State
Department of Social & Health Services

DSHS 22-1248 CA (4/08)